00658296

E71

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២៥ ខែ មីនា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈជាមួយឧបសម្ព័ន្ធសម្ងាត់បំផុត

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ ...បំផុត / Strictly Confidential

អាសន្ន: ...ement Confidentiel

ឈ្មោះមន្ត្រីកត់ត្រា: សាធារណៈ / Public

ហត្ថលេខា:

---

**ញត្តិរបស់ អៀង សារី សុំឲ្យមានសវនាការពេញលេញលើការបំពេញកិច្ចស៊ើបសួរ**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរា

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 30 / 03 / 2011
ម៉ោង (Time/Heure): 09:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសូមស្នើអង្គជំនុំជម្រះសាលាដំបូងបើកសវនាការទៅលើដំណើរការស៊ើបសួរ។ ញត្តិនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះមេធាវីការពារក្តីបានព្យាយាមជាច្រើនដង ដើម្បីទទួលបានព័ត៌មានទាក់ទងនឹងដំណើរការស៊ើបសួរ ហើយព័ត៌មាននេះមិនត្រូវបានគេផ្តល់ឡើយ ។ មេធាវីការពារក្តីមានមូលហេតុដើម្បីជឿជាក់ថាមានកំហុសនៅក្នុងការស៊ើបសួរ ហើយថាការស៊ើបសួរអាចលំអៀង ។ រាល់កំហុស និងភាពលំអៀងនៅក្នុងការស៊ើបសួរអាចប៉ះពាល់ដល់សម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនិងភាគីនាពេលជំនុំជម្រះ។ ចំណុចនេះគឺពិតជាត្រឹមត្រូវ ដោយហេតុថាមេធាវីការពារក្តីត្រូវបានគេហាមឃាត់មិនឲ្យបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងនៅពេលនោះទេ ។ ប្រសិនបើវាពិតដូចការចោទប្រកាន់ថាការស៊ើបសួរផ្តោតតែទៅលើភស្តុតាងដាក់បន្ទុក ជាជាងស្វែងរកឲ្យបានស្មើគ្នានូវភស្តុតាងដោះបន្ទុក នោះឯកសារនៅក្នុងសំណុំរឿងនឹងមិនអាចបង្ហាញរូបភាពច្បាស់ទាក់ទងទៅនឹងទោសកំហុស ឬភាពគ្មានទោសរបស់ជនជាប់ចោទ ហើយនឹងមិនអនុញ្ញាតឲ្យចៅក្រមស្វែងរកការពិតបានឡើយ។ ព័ត៌មានទាក់ទងនឹងដំណើរការស៊ើបសួរ គឺចាំបាច់បន្ថែមទៀតនៅមុនការចាប់ផ្តើមសវនាការជំនុំជម្រះក្តី ពីព្រោះបើមិនដឹងពីការកើតមាននៃកំហុស ឬថាតើការស៊ើបសួរលំអៀងដែរ ឬអត់នោះទេ មេធាវីការពារក្តីនឹងមិនអាចជំទាស់តវ៉ាឲ្យបានត្រឹមត្រូវចំពោះភាពជឿជាក់បានរបស់ភស្តុតាងនៅសវនាការបានឡើយ ហើយមេធាវីការពារក្តីនឹងមិនដឹងតើអ្វីទៅជាភាពកម្សោយដែលកើតមានទាក់ទងនឹងភស្តុតាងនោះទេ។ មេធាវីការពារក្តីទទួលស្គាល់ថាវិធាន ៧៦(៧) ចែងថា “លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ” ។ នៅក្នុងកាលៈទេសៈដូចកើតមាននៅក្នុងករណីបច្ចុប្បន្ននេះ មេធាវីការពារក្តីស្នើសុំឲ្យពិចារណាថាវិធាននេះមិនអាចរារាំងមិនឲ្យមានសវនាការដេញដោលមួយទាក់ទងនឹងកំហុស និងភាពលំអៀងដែលអាចកើតមាននៅក្នុងការស៊ើបសួរបានឡើយ ។ មេធាវីការពារក្តីពុំមាន<u>ផ្លូវណា</u> ដើម្បីលើកឡើងឲ្យបានគ្រប់គ្រាន់ពីកំហុសទាំងនេះ និងភាពលំអៀងនេះរហូតមកដល់ពេលនេះទេ ។ ប្រសិនបើសវនាការមិនត្រូវបានធ្វើឡើងទេនោះ មេធាវីការពារក្តីនឹងមិនទទួលបាននូវដំណោះស្រាយ ដើម្បីកែតម្រូវកំហុសនៅក្នុងកិច្ចស៊ើបសួរនោះទេ ហើយវានឹងនាំឲ្យមានការរំលោភសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទៀតផង ។ មេធាវីការពារក្តីសូមស្នើថាអង្គជំនុំជម្រះសាលាដំបូងកោះហៅអតីតសហចៅក្រមស៊ើបអង្កេត Marcel Lemonde និងសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង អតីតប្រធានអង្គភាពស៊ើបអង្កេត និងវិភាគនៅ កសចស Wayne Bastin មន្ត្រីច្បាប់នៅ កសចស David Boyle អ្នកស៊ើបអង្កេតនៅ កសចស Stephen Heder អ្នកវិភាគនៅ កសព Craig Etcheson និងអ្នកដទៃទៀតដែលអាចមានព័ត៌មានទាក់ទងនឹងដំណើរការ

ស៊ើបសួរ ដើម្បីផ្តល់ភស្តុតាងនៅមុនការចាប់ផ្តើមសវនាការលើអង្គសេចក្តី ។

## I ការចាត់ចំណាត់ថ្នាក់របស់ញត្តិនេះ

១. ញត្តិនេះត្រូវបានដាក់ព្រមជាមួយសំណើសុំចាត់ចំណាត់ថ្នាក់ជា"សាធារណៈ" ។ បញ្ហាជាក់លាក់នានាដែលបានយោងនៅទីនេះ ត្រូវបានចាត់ចំណាត់ថ្នាក់ជាសម្ងាត់ ប៉ុន្តែ មេធាវីការពារក្តីស្នើសុំឱ្យពិចារណាថាពុំមានហេតុផលដែលថាសម្ភារៈទាំងឡាយដែលមាននៅក្នុងញត្តិនេះ មិនអាចចាត់ជាសាធារណៈបាននោះទេ[1]។ ញត្តិនេះត្រូវតែបានចាត់ចំណាត់ថ្នាក់ជាសាធារណៈ សម្រាប់ហេតុផលតម្លាភាព ។ សាធារណជនមានសិទ្ធិពិនិត្យដំណើរការនីតិវិធី ហើយត្រូវតែបានដឹងពីកំហុសណាមួយដែលកើតមាននៅក្នុងដំណើរការស៊ើបសួរ ។ ការចាត់ចំណាត់ថ្នាក់ញត្តិជាសម្ងាត់ គឺគ្រាន់តែបង្កើតការចាប់អារម្មណ៍ថាចៅក្រមជឿជាក់ថាមានលាក់កំបាំងអ្វីមួយ ។ ឧបសម្ព័ន្ធសម្ងាត់បំផុតត្រូវបានដាក់ភ្ជាប់ជាមួយ ដើម្បីដោះស្រាយបញ្ហាមួយដែលត្រូវបានចាត់ចំណាត់ថ្នាក់ថាជា "សម្ងាត់បំផុត" ។ មេធាវីស្នើសុំឱ្យពិចារណាថាឧបសម្ព័ន្ធនេះ ត្រូវតែចាត់ចំណាត់ថ្នាក់ថាជាសាធារណៈផងដែរ ។ មេធាវីការពារក្តីនឹងដាក់សំណើសុំចាត់ចំណាត់ថ្នាក់ឡើងវិញលើឯកសារទាំងអស់ទាក់ទងនឹងបញ្ហាសម្ងាត់បំផុតដែលមាននៅក្នុងឧបសម្ព័ន្ធនេះជាឯកសារសាធារណៈនោះ។

## II. ច្បាប់ជាធរមាន

២. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលបានធ្វើវិសោធនកម្មនៅឆ្នាំ១៩៩៩ ចែងក្នុងផ្នែកពាក់ព័ន្ធថា: "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញា

---

[1] ឧទាហរណ៍ សំណើរបស់មេធាវីការពារក្តីសុំ កសចស ឱ្យផ្តល់តារាងវិភាគដែលអាចភ្ជាប់សម្ភារៈអង្គហេតុនីមួយៗ ជាមួយភស្តុតាងដាក់បន្ទុក ឬ ដោះបន្ទុកដែលពាក់ព័ន្ធនីមួយៗ ព្រមទាំងជាមួយធាតុផ្សំនៃឧក្រិដ្ឋកម្មនីមួយៗដែលបានចោទប្រកាន់ និងធាតុផ្សំនៃទម្រង់នៃការទទួលខុសត្រូវ ត្រូវបានចាត់ចំណាត់ជាសម្ងាត់ ដូចដែលមានចែងនៅក្នុងការឆ្លើយតបរបស់ កសចស។ សំណើ និងចម្លើយតបរបស់ កសចស មិនមានអ្វីជាព័ត៌មានសម្ងាត់នោះទេ ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស ការចម្លើយតបទៅនឹងសំណើរបស់ អៀង សារី សុំឱ្យផ្តល់តារាងវិភាគភស្តុតាង ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០ A372/1, ERN: 00495269-00455269 ។*ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស ការចម្លើយតបទៅនឹងសំណើរបស់ អៀង សារី សុំធ្វើការថតសោតទស្សន៍/ថតសម្លេងរបស់ អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១០ A371/1, ERN: 00495263-00495264 ។

ទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្រី និងសិទ្ធិកុមារ"[2] ។ អនុលោមតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀង "សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរនៃការជំនុំជម្រះក្តី ។ សិទ្ធិបែបនេះជាពិសេសរួមមានសិទ្ធិទទួលបានសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ..."[3] ។ មាត្រា ៣៣ ថ្មីនៃច្បាប់បង្កើត អវតក មានបទប្បញ្ញត្តិស្រដៀងនេះច្រើន[4]។

៣. សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ រួមមានសិទ្ធិត្រូវបានជំនុំជម្រះដោយតុលាការមួយដែលឯករាជ្យនិងឥតលំអៀង ។ អនុលោមតាមមាត្រា ១៤(១) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ "ក្នុងសម្រេចចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយប្រឆាំងមក

---

[2] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ ។

[3] បញ្ជាក់បន្ថែម ។ មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងក្នុងផ្នែកពាក់ព័ន្ធថា "ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមួយដែលមានសមត្ថភាព ឯករាជ្យ និងឥតលំអៀងដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងបទល្មើសព្រហ្មទណ្ឌ ឬសិទ្ធិនិងករណីកិច្ចក្នុងរឿងក្តីរដ្ឋប្បវេណី។ សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទដែលត្រូវជំនុំជម្រះដោយសាលាក្តីឯករាជ្យ និងឥតលំអៀង ក៏ត្រូវបានទទួលស្គាល់នៅក្នុងសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សសំខាន់ៗដទៃទៀតដែរ ។ សេចក្តីប្រកាសជាសកលឆ្នាំ១៩៤៨ ស្តីពីសិទ្ធិមនុស្សចែងនៅក្នុងមាត្រា១០ ថា "មនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាពេញលេញ សុំឱ្យតុលាការដែលឯករាជ្យ និងឥតលំអៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ កាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទល្មើសព្រហ្មទណ្ឌ"។ មាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបឆ្នាំ១៩៥០ ស្តីពីសិទ្ធិមនុស្ស ចែងថា "ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានសវនាការជំនុំជម្រះក្តីដោយយុត្តិធម៌ និងជាសាធារណៈក្នុងពេលវេលាសមស្របដោយតុលាការឯករាជ្យ និងឥតលំអៀង ដែលបង្កើតឡើងដោយច្បាប់" ។ មាត្រា ៨(១) នៃអនុសញ្ញាអាមេរិកកាំងឆ្នាំ១៩៦៩ ស្តីពីសិទ្ធិមនុស្សចែងថា "បុគ្គលគ្រប់រូបមានសិទ្ធិទទួលបាននូវសវនាការកាត់សេចក្តីដោយសាលាក្តីឯករាជ្យ និងឥតលំអៀង ដែលបង្កើតឡើងដោយច្បាប់" ។ មាត្រា ៧(១)(ឃ) នៃធម្មនុញ្ញទ្វីបអាហ្វ្រិកឆ្នាំ១៩៨១ ស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន ចែងថា "មនុស្សគ្រប់រូបត្រូវមានសិទ្ធិដើម្បីឱ្យករណីរបស់ខ្លួន ត្រូវបានកាត់សេចក្តី "នៅក្នុងពេលវេលាសមស្រប" ដោយតុលាការមួយដែលឯករជ្យ និងឥតលំអៀង" ។

[4] មាត្រា ៣៣ ថ្មីចែងថា "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី ។ ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងនៅក្នុងមាត្រា ១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" ។

លើខ្លួន ឬសិទ្ធិ និងករណីកិច្ចនៅក្នុងរឿងក្តីរដ្ឋប្បវេណី ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយសាលាក្តីមួយមានសមត្ថភាព ឯករាជ្យ និងឥតលំអៀង ដែលបង្កើតឡើងដោយច្បាប់" ។

៤. លក្ខខណ្ឌតម្រូវនៃតុលាការមួយដែលឯករាជ្យ និងឥតលំអៀង តម្រូវថាចៅក្រមដែលជាសមាសភាពរបស់តុលាការ ត្រូវតែឯករាជ្យ និងឥតលំអៀង ។ មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាធានានូវឯករាជ្យភាព និងភាពឥតលំអៀងរបស់តុលាការ ដោយបានចែងថា "អំណាចតុលាការជាអំណាចឯករាជ្យ ។ តុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ"[5]។ កិច្ចព្រមព្រៀង និងច្បាប់បង្កើត អវតក បញ្ជាក់ពីបទប្បញ្ញត្តិនេះ ។ ច្បាប់ទាំងពីរនេះចែងថាចៅក្រម "ត្រូវតែឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ"[6] ។

៥. មុខងារមិនលំអៀងនេះ ត្រូវបានចែងបន្ថែមទៀតនៅក្នុងមាត្រា ២ នៃក្រមសីលធម៌ចៅក្រមនៅអវតក ដែលតម្រូវដោយគ្មានការលើកលែងថា:

១. ចៅក្រមត្រូវរក្សានូវភាពមិនលំអៀង និងត្រូវធានាពីការបង្ហាញពីភាពមិនលំអៀងនោះក្នុងការបំពេញមុខនាទីរបស់ខ្លួន ។

២. ចៅក្រមត្រូវចៀសវាងនូវរាល់ទំនាស់ផលប្រយោជន៍ ឬ ស្ថិតនៅក្នុងស្ថានភាពណាមួយដែលគេអាចយល់ឃើញថាមានទំនាស់ផលប្រយោជន៍កើតឡើង[7] ។

## III. អំណះអំណាង

### ក. មានភស្តុតាងគ្រប់គ្រាន់ដើម្បីលើកឡើងថាការស៊ើបសួរមានភាពលំអៀង និងម្យ៉ាងវិញទៀតមានកំហុស

---

[5] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ ។

[6] កិច្ចព្រមព្រៀង មាត្រា ៣(៣) និងមាត្រា ១០ ថ្មីនៃច្បាប់ (បញ្ជាក់បន្ថែម) ។

[7] អនុម័តដោយកិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ ដែលត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ។ សូមមើលមាត្រា៤ នៃក្រមសីលធម៌ចៅក្រមនៅតុលាការ ICC ដែលត្រូវបានអនុម័ត និងចូលជាធរមាននៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៥ ដែលពិពណ៌នាពីមុខងារមិនលំអៀងរបស់ចៅក្រម ដែលប្រើប្រាស់ពាក្យស័ព្ទដូចគ្នា ។

៦. នៅទូទាំងកិច្ចស៊ើបសួរ មេធាវីការពារក្តីប្រឈមមុខនឹងបញ្ហាជាច្រើន ដែលនាំឱ្យមេធាវីការពារក្តីសន្និដ្ឋានថាការស៊ើបសួរមានកំហុស និងលំអៀង ។ ប្រវត្តិនីតិវិធីពេញលេញទាក់ទងនឹងបញ្ហាទាំងនេះមិនអាចលើកឡើងនៅទីនេះបានទេ ដោយសារតែកន្លែងមានកម្រិត ។ បញ្ហាខាងក្រោមនេះជាពិសេសនៅពេលដែលបញ្ហាទាំងនេះត្រូវបានពិចារណារួមគ្នា បង្ហាញថាកំហុសបានកើតឡើង និងភាពលំអៀងហាក់ដូចជាបានកើតមាន ។ កំហុស និងភាពលំអៀងទាំងនេះតម្រូវឱ្យមានសវនាការពេញលេញទៅលើដំណើរការស៊ើបសួរ ។

ក. កសចស ហាក់ដូចជាបានធ្វើសកម្មភាពដោយគ្មានការគោរពដល់សិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ចាប់តាំងពីពេលដែល កសចស ទទួលបានសំណុំរឿង អៀង សារី ។ នៅក្នុងដីកាសម្រេចលើកទីមួយរបស់ខ្លួនស្តីពីការឃុំខ្លួនបណ្តោះអាសន្ន និងដោយពុំបានផ្តល់ការជូនដំណឹងណាមួយដល់ភាគីថាបញ្ហាទាំងនេះនឹងត្រូវលើកមកដោះស្រាយ កសចស បានសម្រេចថាព្រះរាជក្រិតលើកលែងទោសរបស់ អៀង សារី និងគោលការណ៍មិនជំនុំជម្រះទោសពីរដង *(ne bis in idem)* នឹងមិនរារាំងមិនឱ្យមានការជំនុំជម្រះទោសបច្ចុប្បន្ននេះ[8]។ ភាគីមិនទទួលបានសិទ្ធិផ្តល់មតិយោបល់ណាមួយទៅលើបញ្ហាស្មុគស្មាញនានានៅមុន កសចស ចេញសេចក្តីសម្រេចរបស់ខ្លួន ។ មេធាវីការពារក្តីយល់ឃើញថា កសចស ប៉ុនប៉ងបោះបង់ចោលបញ្ហាទាំងនេះនៅមុនមេធាវីការពារក្តីអាចធ្វើសកម្មភាព ។

ខ. កសចស ជ្រើសរើសឱ្យចូលបំរើការងារបុគ្គលិកចំនួនពីររូបដែលបង្ហាញឱ្យឃើញច្បាស់

[8] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាសម្រេចស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, C22, ERN: 00153253-00153260 ។ កសចស ចេញដីកាសម្រេចមួយទៀត ដែលនៅក្នុងដីកានេះហាក់បីដូចជាត្រូវបានធ្វើឡើងដើម្បីធ្វើឱ្យបានសម្រេចនូវលទ្ធផលដែលខ្លួនប៉ងប្រាថ្នា ជាជាងត្រូវបានធ្វើឡើងដោយផ្អែកលើភស្តុតាងដែលមាន ដីកាសម្រេចមួយនេះបានបង្គាប់ឱ្យលោក អៀង សារី ត្រូវតែឃុំខ្លួន ដោយសារហានិភ័យ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខរបស់គាត់ ក៏ដូចជាសន្តិសុខរបស់សាក្សី និងថាគាត់អាចរត់គេចខ្លួន ។ កសចស ចេញដីកាសម្រេចនេះ បើទោះបីការណ៍ដែលថាលោក អៀង សារី បានរស់នៅដោយសេរីនៅក្នុងប្រទេសកម្ពុជាជាច្រើនឆ្នាំមកហើយ ថ្វីបត្បិតតែគាត់ដឹងថាគាត់អាចជាជនសង្ស័យម្នាក់នៅ អវតក ក៏ដោយចុះ តែគាត់មិនបានរត់គេច មិនបានគំរាមកំហែងសណ្តាប់ធ្នាប់សាធារណៈ ឬ សាក្សី និងសន្តិសុខរបស់គាត់ក៏មិនដែលបានគេគំរាមដែរ ។

នូវភាពលំអៀង:[9]

- ដោយមិនបានពិចារណាយ៉ាងពិតប្រាកដពីមុខងាររបស់ខ្លួន ដែលមិនលំអៀងជាដាច់ខាត

---

[9] សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំព័ត៌មានទាក់ទងនឹងទំនាស់ផលប្រយោជន៍ជាក់ស្តែងចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ A121, ERN: 00157760-00157761 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំព័ត៌មានទាក់ទងនឹងការកើតឡើងនូវភាពលំអៀងដែលមើលឃើញយ៉ាងច្បាស់ និងអត្ថិភាពនៃទំនាស់ផលប្រយោជន៍ជាក់ស្តែងរបស់មន្ត្រីច្បាប់នៅ កសចស David Boyle, A162, ERN: 00165542-00165547 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស លិខិតមានចំណងជើងថា "សំណើទាក់ទងនឹងការសាកសួរលោក អៀង សារីស្តីពីលក្ខខណ្ឌនៃការឃុំខ្លួនគាត់ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨" ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨, A121/II, ERN: 00185454-00185456, ទំព័រ ២-៣ ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស លិខិតមានចំណងជើងថា "សំណើទាក់ទងនឹងការលេចឡើងនៃភាពលំអៀងដែលមើលឃើញយ៉ាងច្បាស់ និងទំនាស់ផលប្រយោជន៍ទាក់ទងនឹង MM S. Heder និង D. Boyle ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៨ A121/III, ERN: 00193591 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០៨) បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស លើសំណើរបស់មេធាវីការពារក្តីសុំព័ត៌មានទាក់ទងនឹងការកើតឡើងនូវភាពលំអៀងដែលមើលឃើញយ៉ាងច្បាស់ និងអត្ថិភាពនៃទំនាស់ផលប្រយោជន៍ជាក់ស្តែងរបស់មន្ត្រីច្បាប់នៅ កសចស David Boyle ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨ A162/III/1, ERN: 00195028-00195035 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០៨) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងលិខិតទាក់ទងនឹងសំណើរបស់មេធាវីការពារក្តីសុំព័ត៌មានទាក់ទងនឹងការកើតឡើងនូវភាពលំអៀងដែលមើលឃើញយ៉ាងច្បាស់ និងអត្ថិភាពនៃទំនាស់ផលប្រយោជន៍ជាក់ស្តែងរបស់មន្ត្រីច្បាប់នៅ កសចស David Boyle ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ A162/III/6, ERN: 0022`204-00221208 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំព័ត៌មានទាក់ទងនឹងការលេចឡើងនៃភាពលំអៀងដែលមើលឃើញយ៉ាងច្បាស់ និងទំនាស់ផលប្រយោជន៍ទាក់ទងនឹង S. Heder ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ A252 ERN: 00282718-00282722 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស លិខិតមានចំណងជើងថា "សំណើរបស់លោកសុំព័ត៌មានទាក់ទងនឹង S. Heder" ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ A252/2 ERN: 00335321-00335322 ។ *ករណី អៀង សារី* ០០២/៨-០៧-២០០៩-អវតក-កសចស/អបជ បណ្តឹងរបស់ អៀង សារី សុំប្តឹងជិតចិត្តប្រឆាំងនឹងអ្នកស៊ើបអង្កេតនៅ កសចស Stephen Heder និងមន្ត្រីច្បាប់នៅការិយាល័យសហចៅក្រមស៊ើបអង្កេត David Boyle ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩ 1, ERN: 00348412-00348440 ។ *ករណី អៀង សារី* ០០២/០៨-០៧-២០០៩-អវតក-កសចស/អបជ សាលដីកាលើបណ្តឹងរបស់ជនត្រូវចោទសុំជិតចិត្តប្រឆាំងនឹង Dr. Stephen Heder និង David Boyle ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩ 3, ERN: 00378097-00378103 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់ កសព សុំតែងតាំងអ្នកជំនាញ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ D281/2, ERN: 00429181-00429187 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស សេចក្តីសម្រេចលើសំណើរបស់ កសព សុំតែងតាំងអ្នកជំនាញ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ D281/3, ERN: 00464901-00464904 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើរបស់ អៀង សារី សុំដាក់កម្រិតវិសាលភាពនៃភារកិច្ចរបស់អ្នកស៊ើបអង្កេត កសចស Stephen Heder D377/1, ERN: 00505302 ។

កសចស បានជ្រើសរើសលោក David Boyle ឲ្យមកចូលធ្វើការជាមន្ត្រីច្បាប់ បើទោះបីជាលោក David Boyle បានធ្វើសេចក្តីថ្លែងជាក់លាក់ដែលបង្ហាញពីភាពលំអៀងក៏ដោយ ជាក់ស្តែងលោក David Boyle បានថ្លែងនៅឆ្នាំ ២០០៥ ថា:

> ករណី អៀង សារី គឺជាឧទាហរណ៍មួយបញ្ជាក់ពីបញ្ហានានាដែលនឹងកើតឡើងនៅចំពោះមុខតុលាការកម្ពុជា ។ អៀង សារី ត្រូវបានលើកលែងទោសតាមច្បាប់រដ្ឋធម្មនុញ្ញចំពោះឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន និងទទួលបានការលើកលែងពីការកាត់សេចក្តីតាមច្បាប់ឆ្នាំ១៩៩៤ ។ ថាតើការលើកលែងទោសស្របតាមច្បាប់ធម្មនុញ្ញនេះ អនុវត្តនៅចំពោះមុខសាលាក្តីខ្មែរក្រហមបានក្នុងកម្រិតណា? សំណួរនេះត្រូវទុកឲ្យតុលាការជាអ្នកសម្រេច ។ សំណួរទាំងអស់នេះនឹងត្រូវលើកឡើងដោយមេធាវីការពារក្តី *និងត្រូវតែបានដោះស្រាយពីឥឡូវនេះទៅ ដើម្បីបញ្ចៀសមេធាវីដែលមានទេពកោសល្យ មិនឲ្យពន្យឹតការជំនុំជម្រះក្តីដែលមានរយៈពេលបីឆ្នាំ នឹងមិនអាចបញ្ចប់បានឡើយ ។ គេអាចមានចម្លើយពីរដើម្បីដោះស្រាយបញ្ហាទាំងនេះបានមួយផ្នែក ។ ចម្លើយទីមួយ គឺថាចៅក្រមបន្ទាប់ពីបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាមួយនឹងព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត ត្រូវរិះរកជាបន្ទាន់នូវនីតិវិធីដែលអាចអនុវត្តបានសម្រាប់តុលាការនេះ ។ ពួកគេមិនអាចកែប្រែច្បាប់បានទេ តែពួកគេអាចរកដំណោះស្រាយថា តើច្បាប់មានន័យយ៉ាងដូចម្តេចនោះ*[10] ។

លោក David Boyle ហាក់ដូចជាមានឥទ្ធិពលលើចំណាត់ការរបស់ កសចស ក្នុងបញ្ហានៃការលើកលែងទោស និងការមិនជំនុំជម្រះពីរដងក្នុងអំពើល្មើសតែមួយ *ne bis in idem* នៅក្នុងដីកាសម្រេចស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ។

- កសចស ជ្រើសរើស Stephen Heder ឲ្យចូលបំរើការងារជាអ្នកស៊ើបអង្កេត បន្ទាប់ពីលោក Stephen Heder បានបំរើការងារនៅ កសព ដែលបានតាក់តែងដីកាសន្និដ្ឋានបញ្ជូន

---

[10] របាយការណ៍ពីសន្និសិទដែលធ្វើនៅទីក្រុងភ្នំពេញ នៅថ្ងៃទី២-៣ ខែមីនា ឆ្នាំ២០០៥ រៀបចំដោយអង្គការ FIDH, LICADHO ADHOC កម្មវិធីតុលាការព្រហ្មទណ្ឌអន្តរជាតិ: សន្និយោគរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និង សាលាក្តីខ្មែរក្រហម: កន្លែងរបស់ជនរងគ្រោះ, 3. B. David Boyle ។ ក្របខណ្ឌច្បាប់របស់សាលាក្តីខ្មែរក្រហមនៅទំព័រទី៨ (បញ្ជាក់បន្ថែម) ។ អាចរកបាននៅ: http://www.vrwg.org/Publications/02/FIDHcambodge420ang.pdf.

រឿងឲ្យស៊ើបសួរប្រឆាំងនឹងលោក អៀង សារី ។ អ្វីដែលសំខាន់នោះលោក Heder ត្រូវបានគេស្នើសុំឲ្យពង្រាងការចោទប្រកាន់ប្រឆាំងនឹងលោក អៀង សារី ហើយបន្ទាប់មកគាត់ធ្វើការស៊ើបអង្កេតទៅលើការចោទប្រកាន់ដែលដូចគ្នាពិតៗ ។ លោក Heder ក៏អាចត្រូវបានជួលដោយភ្នាក់ងារសម្ងាត់ CIA នៅក្នុងអំឡុងពេលពាក់ព័ន្ធទៅនឹងការចោទប្រកាន់ដែលអាចបង្កើតទំនាស់ផលប្រយោជន៍[11] ។ គាត់ក៏ជាអ្នកនិពន្ធម្នាក់នៃសៀវភៅ "បេក្ខជនទាំងប្រាំពីរនាក់សម្រាប់ការកាត់សេចក្តី: ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៃខ្មែរក្រហម ដែលរួមទាំងលោក អៀង សារី ដែលជាបេក្ខជនម្នាក់នៃ "បេក្ខជនទាំងប្រាំពីរនាក់នេះ"[12] (SEVEN CANDIDATES FOR PROSECUTION: ACCOUNTABILITY FOR THE CRIMES OF THE KHMER ROUGE) ។

គ. កសចស បានតែងតាំងអ្នកប្រជាសាស្ត្រដែលមិនមានគុណវុឌ្ឍិ និងលំអៀងជាក់ស្តែងជាជំនាញប្រជាសាស្ត្រដែលត្រូវបានគេសន្មតថាមិនលំអៀង[13] និងបានបដិសេធសំណើច្រំដែលរបស់មេធាវីការពារក្តី សុំតែងតាំងអ្នកជំនាញបន្ថែម ដើម្បីធ្វើបដិកម្មតបវិញទៅនឹងអ្នកជំនាញដែលលំអៀង និងខ្វះជំនាញ[14] ។

ឃ. កសចស ហាមឃាត់លោក អៀង សារី មិនឲ្យជួបមុខប្រពន្ធរបស់គាត់នៅមន្ទីរឃុំឃាំងដោយបញ្ជាក់ដោយគ្មានការពន្យល់បន្ថែមថា "ពិចារណាពីកិច្ចស៊ើបសួរដែលកំពុងបន្ត...

---

[11] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំព័ត៌មានទាក់ទងនឹងការលេចឡើងនៃភាពលំអៀងដែលមើលឃើញយ៉ាងច្បាស់ និងទំនាស់ផលប្រយោជន៍ ទាក់ទងនឹង S. Heder ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ A252 ERN: 00282718-00282722 ។

[12] STEPHEN HEDER & BRIAN TITTEMORE, បេក្ខជន ៧នាក់សម្រាប់ការកាត់ទោស៖ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម (២០០៤) (SEVEN CANDIDATES FOR PROSECUTION: ACCOUNTABILITY FOR THE CRIMES OF THE KHMER ROUGE (2004).

[13] *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាសម្រេចចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ D140, ERN: 00287168-00287172។

[14] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើរបស់ អៀង សារី សុំតែងតាំងអ្នកជំនាញប្រជាសាស្ត្របន្ថែម ចុះថ្ងៃទី១៨ ខែ សីហា ២០០៩ ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើរបស់ អៀង សារី សុំតែងតាំងអ្នកជំនាញប្រជាសាស្ត្របន្ថែមម្នាក់ដើម្បីពិនិត្យឡើងវិញទៅលើរបាយការណ៍ជំនាញដែលដាក់ដោយអ្នកស្រី Tabeau និងលោក They Kheam, នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១០ ERN: 00425270-00425285 ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាសម្រេចលើសំណើរបស់ អៀង សារី សុំតែងតាំងអ្នកជំនាញប្រជាសាស្ត្របន្ថែមម្នាក់ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ERN: 00464873-00464875 ។

យើងមិនមានផែនការផ្លាស់ប្តូរលក្ខខណ្ឌ ដែលកំពុងអនុវត្តចំពោះការសួរសុខទុក្ខគ្នាពេលនេះទេ ។ អាស្រ័យហេតុនេះ ពុំមានការជួបមុខគ្នារវាង អៀង ធីរិទ្ធ និង កូនក្តីរបស់លោកនៅពេលនេះទេ”[15] ។ សេចក្តីសម្រេចរបស់ កសចស ត្រូវបានបដិសេធចោលនៅបណ្តឹងឧទ្ធរណ៍ ។ អង្គបុរេជំនុំជម្រះបានគូសបញ្ជាក់ថា វាមានលក្ខណៈមិនច្បាស់ថាតើការហាមឃាត់ ឬការដាក់កំហិតការជួបមុខគ្នារវាងលោក អៀង សារី និងអ្នកស្រី អៀង ធីរិទ្ធ ដែលបានរៀបការនឹងគ្នាអស់រយៈពេល ៥៧ មកហើយ នឹងការពារកិច្ចស៊ើបសួរដោយរបៀបណានោះទេ”[16] ។ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសម្រេចរបស់ កសចស គឺជាវិធានការដែលមានលក្ខណៈចាប់បង្ខំ ដែលមិនមែនជាតម្រូវការតឹងរ៉ឹងដល់ដំណើរការនីតិវិធីនោះទេ[17] ។

ង. កសចស ហាមឃាត់មេធាវីការពារក្តីមិនឱ្យដំណើរការស៊ើបសួរដោយខ្លួនឯងក្នុងអំឡុងពេលស៊ើបសួរ ។ កសចស បានបញ្ជាក់:

នៅចំពោះមុខតុលាការនេះ អំណាចដឹកនាំការស៊ើបសួរត្រូវបានប្រគល់ឱ្យទាំងស្រុងទៅសហចៅក្រមស៊ើបអង្កេតឯករាជ្យទាំងពីរ និងមិនមែនភាគីទេ ។ ពុំមានបទប្បញ្ញត្តិដែលអនុញ្ញាតិឱ្យភាគីបំពេញកិច្ចស៊ើបសួរ ជំនួសឱ្យសហចៅក្រមស៊ើបអង្កេតទាំងពីរនេះទេ ដែលអាចកើតមាននៅក្នុងប្រព័ន្ធនីតិវិធីដទៃទៀត...។ ហេតុដូច្នេះ សមត្ថភាពរបស់ភាគីដើម្បីអន្តរាគមន៍ ត្រូវបានកម្រិតត្រឹមតែការស៊ើបសួរបឋម ដែលចាំបាច់សម្រាប់ការអនុវត្តសិទ្ធិរបស់ពួកគេដើម្បីស្នើសុំបំពេញការស៊ើបសួរប៉ុណ្ណោះ[18] ។

ចំណុចនេះបានដាក់ឱ្យមេធាវីការពារក្តីក្នុងស្ថានភាពមួយដែលមិនសមភាពគ្នា បើប្រៀប

---

[15] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស អនុស្សរណៈ ការជួបមុខគ្នារវាង អៀង សារី និង ប្រពន្ធរបស់គាត់ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨ A104/I, ERN: 00159511-00159511 ។

[16] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការជួបប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទ និងប្រពន្ធរបស់គាត់ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ នៅកថាខណ្ឌទី១៩-២០ ERN: 00184951-00184956 ។

[17] ដូចខាងលើ នៅកថាខណ្ឌទី១៥-២០ ។

[18] *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក-កសចស លិខិតពី កសចស ផ្ញើទៅមេធាវីការពារក្តី នួន ជា កម្មវត្ថុ: លិខិតឆ្លើយតបទៅនឹងលិខិតរបស់លោក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ទាក់ទងនឹងបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ នៅ A110/1, ERN: 00157729-00157730 ទំព័រទី២ (បញ្ជាក់បន្ថែម) ។

ធៀបជាមួយសហព្រះរាជអាជ្ញា ដោយសារតែសហព្រះរាជអាជ្ញាបានធ្វើស៊ើបអង្កេតករណី ០០២[19] ជាងមួយឆ្នាំមកហើយ មុនពេលបញ្ជូនសំណុំរឿងនេះទៅ កសចស[20] ។ នៅពេលដែលមេធាវីការពារក្តី ព្យាយាមធ្វើការបញ្ជាក់ថាតើ និងនៅកម្រិតណាដែលមេធាវីការពារក្តីអាចបំពេញកិច្ចស៊ើបសួរណាមួយបានដែរ ឬអត់[21] កសចស បដិសេធមិនផ្តល់ការឆ្លើយតបទូលំទូលាយ ហើយជំនួសមកវិញបានចេញការព្រមានប្រឆាំងមេធាវីការពារក្តី[22] ។

ច. កសចស បានខកខានមិនបានបង្ហាញឲ្យបានទូលំទូលាយអំពីវិធីសាស្ត្រស៊ើបសួររបស់ខ្លួនរួមទាំង:[23] **ក)** ច្បាប់នីតិវិធីដែល កសចស និង អ្នកស៊ើបអង្កេតរបស់ខ្លួន យកមកអនុវត្ត **ខ)** ការធ្វើផែនការ និងយុទ្ធសាស្ត្រទូទៅនៃការស៊ើបសួរ **គ)** គុណវឌ្ឍិ និងបទពិសោធ

---

[19] កសព ក៏បានស៊ើបសួរលើករណី ០០១ និងបានចូលរួមការជំនុំជម្រះក្តីនៅក្នុងករណី ០០១ នេះដែរ ដែលមូលដ្ឋានបទល្មើសនៃករណីនេះ ស្រដៀងគ្នានឹងករណី ០០២ ដែរ ។ ចំណុចនេះបានដាក់ឲ្យ កសព និង មេធាវីការពារក្តីមិនមានស្ថានភាពស្មើភាពគ្នា។

[20] កសព បានបើកការស៊ើបសួរករណី ០០២ នៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០០៦ ។ សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរ លេខ ០០៨ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ D3 ទំព័រ១។

[21] សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស លិខិតពីមេធាវីការពារក្តីផ្ញើទៅសហចៅក្រមស៊ើបអង្កេត ស្នើសុំថាតើ និងនៅកម្រិតណា មេធាវីការពារក្តីអាចបំពេញកិច្ចស៊ើបសួរបានដោយខ្លួនឯង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០១០ D346, ERN: 00446993-00446995 ។

[22] សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាព្រមានដោយអនុវត្តតាមវិធាន ៣៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ERN: 00478513-00478519 ។ “សហចៅក្រមស៊ើបអង្កេតយល់យ៉ាងច្បាស់ថាមេធាវីការពារក្តី អៀង សារី ព្យាយាមសំអាងសំណើសុំបំពេញកិច្ចស៊ើបសួររបស់ខ្លួន តាមរយៈការព្រងោលការអនុវត្តប្រព័ន្ធច្បាប់ Civil Law ដែលក្នុងនោះដំណើរការនៃកិច្ចស៊ើបសួរ ត្រូវធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតតែមួយគត់...។ សហចៅក្រមស៊ើបអង្កេតសូមព្រមានសហមេធាវី អៀង សារី ដោយអនុវត្តតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុងថា ពួកគេត្រូវបានហាមឃាត់មិនឲ្យដំណើរការស៊ើបសួរដោយខ្លួនឯង ហើយការបំពានលើការហាមឃាត់នេះនឹងនឹងប្រឈមមុខនឹងការដាក់ទណ្ឌកម្ម” ។ ដូចខាងលើ កថាខណ្ឌទី៨-៩។

[23] ជាយថាហេតុ កសចស បានឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី សុំព័ត៌មាននេះ ប៉ុន្តែ ចម្លើយតបនេះមានភាពមិនច្បាស់លាស់ និងទូទៅពេក ដែលពិបាកឲ្យមេធាវីការពារយកមកប្រើប្រាស់ ។ សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើលើកទីបី របស់ អៀង សារី សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ D171, ERN: 00330819-00330834 (“សំណើលើកទី៣ សុំបំពេញកិច្ចស៊ើបសួរ”) ។ *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ២៩) បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ កសចស ទៅលើសំណើលើកទី៣ សុំបំពេញកិច្ចស៊ើបសួររបស់ អៀង សារី ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៨ D171/4/1, ERN: 00384821-00384843 ។

របស់អ្នកស៊ើបអង្កេត និងបទដ្ឋាននៃនីតិវិធីប្រត្តិការ និង **ឃ)** ការស្វែងរក និងការវិភាគភស្តុតាងដោះបន្ទុកដោយ កសចស ដែលបានក្តោបក្តាប់ព័ត៌មានអំពីជម្រើសផ្សេងៗនៃទ្រឹស្តីរបស់ព្រឹត្តិការណ៍ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលត្រូវបានពិចារណាដោយ កសចស និងព័ត៌មានស្តីពីរបៀបដែលជម្រើសផ្សេងៗរបស់ទ្រឹស្តីត្រូវបានប្រែក្លាយទៅជាប្រព័ន្ធសម្រាប់ការកំណត់អត្តសញ្ញាណ ការស្វែងរក និងការវិភាគភស្តុតាងដោះបន្ទុក[24] ។ ការខកខានមិនបានផ្តល់ព័ត៌មាននេះ មានន័យថាកសចស បានធ្វើសកម្មភាពដោយមិនបានពិចារណាការព្រួយបារម្ភស្របច្បាប់របស់មេធាវីការពារក្តីអំពីការបំពេញកិច្ចស៊ើបសួររបស់ កសចស[25] ។

ឆ. កសចស នៅតែខកខានមិនបានបង្ហាញពីវិធីសាស្ត្រនៃការស៊ើបអង្កេតរបស់ខ្លួនទាក់ទងនឹងវិធីដែលខ្លួនកំណត់ថាតើសម្ភារៈអ្វីខ្លះដែលទទួលបានដោយការធ្វើទារុណកម្ម ឬក៏មិនបានបង្ហាញថាតើអ្វីខ្លះជាសម្ភារៈដែលបានមកពីការធ្វើទារុណកម្ម ហើយព័ត៌មានដែលបានមកពីការធ្វើទារុណកម្ម កសចស យកទៅធ្វើអ្វីខ្លះ ក៏ទេដែរ ទោះបីជាមានការស្នើសុំព័ត៌មាន

[24] ព័ត៌មាននេះត្រូវបានស្នើសុំដោយមេធាវីការពារក្តីនៅក្នុង *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើលើកទីបី របស់ អៀង សារី សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ D171, ERN: 00330819-00330834 (“សំណើលើកទី៣ សុំបំពេញកិច្ចស៊ើបសួរ”) ។ ក្រោយមក សំណើបែបនេះត្រូវបានដាក់រួមគ្នាដោយមេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន។ សូមមើល *ករណី នួន ជា* ០០២/១៩-០៩-២០០៧-អវតក-កសចស សេចក្តីជូនដំណឹងអំពីការចូលរួមជាមួយសំណើលើកទី៣ របស់ អៀង សារី សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ D171/2, ERN: 00337488-00337489 ។ *ករណី ខៀវ សំផន* ០០២/១៩-០៩-២០០៧-អវតក-កសចស ការជូនដំណឹងអំពីការអនុម័តយកសំណើលើកទី៣ របស់ អៀង សារី សុំបំពេញកិច្ចស៊ើបសួរ វិធាន ៥៥-១០ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ D171/3, ERN: 00379332-00379333 ។

[25] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ២៩) បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតរបស់ កសចស ទៅលើសំណើលើកទី៣ សុំបំពេញកិច្ចស៊ើបសួររបស់ អៀង សារី ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ D171/4/1, ERN: 00384821-00384843។*ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ២៩) បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្មតតរបស់ កសចស ទៅលើសំណើរបស់ អៀង សារី ទាក់ទងនឹងការកំណត់អត្តសញ្ញាណ និងការផ្អែកលើភស្តុតាងតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩ D130/7/3/1, ERN: 00399297-00399327 ។

បែបនេះពីមេធាវីការពារក្ដីក៏ដោយ[26] ។

មេធាវីការពារក្ដីមានការព្រួយបារម្ភព្រោះ កសចស បានលើកឡើងថា ក្នុងស្ថានភាពមួយចំនួន ខ្លួនប្រហែលជានឹងពឹងផ្អែកលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម[27]។ ឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្ដីសុំការបញ្ជាក់ពីការប្រើប្រាស់ភស្តុតាងរបស់ កសចស ដែលទទួលបានតាមរយៈការធ្វើទារុណកម្ម កសចស បានលើកឡើងថា៖

ការវាយតម្លៃឲ្យបានពេញលេញទៅលើភស្តុតាងបែបនេះមិនអាចធ្វើទៅបានទេ *"រហូតទល់តែនៅពេលបញ្ចប់ការស៊ើបអង្កេត នៅពេលដែលសំណុំរឿងត្រូវបានគេចាត់ទុកថាចប់សព្វគ្រប់"* ។ វាទើបតែពេលដែលបំណែកនីមួយៗនៃភស្តុតាងសំខាន់ ឬភស្តុតាងរាយរងដែលយើងបានបង្ហាញនៅពេល ដែលការលើកឡើងពីបញ្ហានៃការធ្វើទារុណកម្មត្រូវបានគេវាយតម្លៃម្តងមួយៗបន្ទាប់ពីការស៊ើបអង្កេតបានចប់ទេ ទើបសំណើរបស់មេធាវីការពារក្ដីអាចត្រូវបានបំពេញក្នុងផ្ទៃរឿងនៃដីកាដំណោះស្រាយ[28]។

ប៉ុន្តែ កសចស មិនបានបំពេញសំណើរបស់មេធាវីការពារក្ដីក្នុងផ្ទៃរឿងនៃដីកាដំណោះស្រាយឡើយ ។ តាមពិត ដីកាដំណោះស្រាយ ពឹងផ្អែកលើភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម[29] ដោយគ្មានការពន្យល់អ្វីទាំងអស់ទោះបីជាមានការបញ្ជាក់អះអាងពីអង្គបុរេ

---

[26] សូមមើល ឧទាហរណ៍ *ករណី អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/ កសចស, សំណើទាក់ទងនឹងការទទួលស្គាល់របស់ កសចស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលទទួលបាន តាមរយៈការធ្វើទារុណកម្ម, ចុះថ្ងៃទី ៧ ខែសីហា ២០០៩, ឯកសារ D/130/7/21, ERN: 00360855-00360856។

[27] សូមមើល ករណី អៀង សារី សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/ កសចស, ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬអាចបានមកតាមរយៈការធ្វើទារុណកម្ម, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩, ឯកសារ D130/8, ERN: 00355926-00355933, កថាខណ្ឌទី២៣ ដល់២៨។

[28] *ករណី អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/ កសចស, លិខិតពី កសចស, កម្មវត្ថុ៖ សំណើទី១៥របស់នួន ជា សុំបើកកិច្ចស៊ើបសួរ, លិខិតពាក់ព័ន្ធមកពីមេធាវីការពារក្ដីលោក អៀង សារី ទាក់ ទងនឹងភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម, ចុះថ្ងៃទី៣០, ខែតុលា ឆ្នាំ២០០៩, ឯកសារ ERN: 00398434-00398436, ទំព័រទី៣។

[29] ឧទាហរណ៍ កថាខណ្ឌទី១១៨៨ នៃដីកាដំណោះស្រាយ បានដកស្រង់ពីចម្លើយសារភាពរបស់ ប៉ែន ធួក ហៅ វ៉ន វ៉េត យកមកគាំទ្រការអះអាងដែលថា "ខៀវ សំផន ហាក់បីដូចជាបានឃើញការចាប់ខ្លួន វ៉ន វ៉េត", ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៨។ ជាងនេះទៅទៀត វាច្បាស់ណាស់ថា កសចស បានពឹងផ្អែកទៅលើធនធានបន្ទាប់បន្សំជាច្រើនដូចជាសៀវភៅដែលសរសេរដោយលោក David Chandler និង Steve Heder។ សៀវភៅទាំងនេះ ផ្អែកលើចម្លើយសារភាពដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃ

ជំនុំជម្រះថា៖ ទោះបីជាក្នុងដីកាដំណោះស្រាយ គ្មានការសង្កេតផ្ទុយពី កសចស ក៏ដោយ មាត្រា១៥នៃ [អនុសញ្ញាស្តីពីទារុណកម្ម] ត្រូវតែយកមកអនុវត្តឱ្យបានតឹងរឹង។ វាគ្មានឱកាសកំណត់ពីការពិត ឬក៏ការប្រើប្រាស់ចម្លើយដែលបានមកពីការធ្វើទារុណកម្មឡើយ[30]។

ជ. យោងតាមលោក Wayne Bastin អតីតប្រធានអង្គភាពវិភាគ និងស៊ើបអង្កេត[31] របស់ កសចស ចៅក្រម Lemonde បានប្រកាសប្រាប់អ្នកស៊ើបអង្កេតអន្តរជាតិរបស់ កសចស ថាលោក "**ចង់ឱ្យយើងស្វែងរកភស្តុតាងដាក់បន្ទុកឱ្យបានច្រើនជាភស្តុតាងដោះបន្ទុក**[32]"។

---

ខ្លឹមសារអត្ថបទរបស់ខ្លួន។ ឧទាហរណ៍, ជើងទំព័រ ៣៧ ដល់៣៩ នៃដីកាដំណោះស្រាយពឹងផ្អែកលើ DAVID P. CHANDLER, បងធំទី១៖ ជីវប្រវត្តិនយោបាយរបស់ ប៉ុល ពត, ទំព័រ ៦៣ ដល់៦៤, ៦៧ ដល់៦៩, ១៩១, ២០១ ដល់២០២ (ឆ្នាំ ១៩៩៩)។ ទំព័រទាំងនេះក្នុងសៀវភៅដែលមានចំណងជើងថា បងធំទី១៖ ជីវប្រវត្តិនយោបាយរបស់ ប៉ុល ពត ពឹងផ្អែកលើចម្លើយសារភាពរបស់ សៀត ឆែ, ជូ ជេត, ឈឹម សំអោក, ឃៀង ស៊ីមហាន, អ៊ឹម នែម, សោម ជា, វ៉ន វ៉េត, កែវ មុនី, កុល ថៃ, និង កែវ មាស។ ឧទាហរណ៍មួយផ្សេងទៀត ជើងទំព័រ៤១ និង៤២ នៃដីកាដំណោះស្រាយ បានដកស្រង់ STEVE HEDER, CAMBODIAN COMMUNISM AND THE VIETNAMESE MODEL 88, 92, 109-10 (White Lotus Press 2004), ទំព័រទាំងនេះក្នុងសៀវភៅរបស់លោក Heder ពឹងផ្អែកទៅលើចម្លើយសារភាពរបស់ សោម ជា, ប៊ូ ផាត, ស្វ គីម អាន, តូច ផែម, មា ឈួន, កែ សាន និង គង់ សុផល។

[30] *ករណី អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/ កសចស (អបជ៣១), សេចក្តីសម្រេចលើភាពអាចទទួលយកបានលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងការបដិសេធដែមមានការសន្និដ្ឋានទុកជាមុនរបស់ កសចស ប្រឆាំងនឹងសំណើរបស់ អៀង សារី ទាក់ទងទៅនឹងការទទួលស្គាល់របស់ កសចស នូវភស្តុតាង និងការសំអាងទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម, ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១០, D130/7/3/5, ERN: 00512912-00512924, កថាខណ្ឌទី ៣៨ (គូសបញ្ជាក់បន្ថែម)។

[31] ឥឡូវនេះ លោក Bastin កំពុងបម្រើការជាមន្ត្រី ប៉ូ លីស ក្នុងប្រទេស អូស្ត្រាលី។ គាត់បានបម្រើការអស់រយៈពេល៣១ឆ្នាំ ជាពិសេសពាក់ព័ន្ធបទឧក្រិដ្ឋ និងមនុស្សឃាតដែលបានរៀបចំទុកមុនយ៉ាងល្អិតល្អន់ ហើយ តួនាទីសំខាន់របស់ គឺជាអ្នកចាត់ចែងក្នុងការស៊ើបអង្កេត។ កាលពីមុន គាត់បានបម្រើការ១២ខែនៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ដែលនៅទីនោះគាត់គឺជាប្រធានអង្គភាពស៊ើបអង្កេត។ គាត់គឺជាអ្នកស៊ើបអង្កេតជាន់ខ្ពស់ប្រចាំគណៈកម្មការឯករាជ្យពិសេសរបស់អង្គការសហប្រជាជាតិដើម្បីស៊ើបអង្កេត Timor Leste ក្នុងឆ្នាំ២០០៦ និងជាអ្នកទទួលខុសត្រូវក្នុងការបង្កើតអង្គភាពស៊ើបអង្កេតនៅ អវតក ក្នុងឆ្នាំ២០០៧។ លោកបានវិលត្រឡប់មក អវតក វិញក្នុងឆ្នាំ២០០៨ ហើយទទួលតំណែងជាប្រជានអង្គភាពស៊ើបអង្កេត និងវិភាគ។

[32] សូមមើល *ករណី អៀង សារី* សំណុំរឿង ០០២/០៩-១០-២០០៩- អវតក/ អបជ (១), បណ្តឹងរបស់ អៀង សារី សុំដិតចិត្តចៅក្រម Marcel Lemonde និងសំណើសុំឱ្យមានសវនាការជាសាធារណៈ, ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩, ឯកសារ 1, ERN: 00386956-00386968, សេចក្តីផ្តើម, ឧបសម្ព័ន្ធ១។

00658310



កិច្ចប្រជុំនេះធ្វើឡើងដោយគ្មានវត្តមានចៅក្រម យូ ប៊ុនឡេង ឬក៏អ្នកស៊ើបអង្កេតជាតិដទៃទៀតរបស់ កសចស ឡើយ[33]។ គួរឲ្យកត់សម្គាល់ផងដែរថា ចៅក្រម Lemonde មិនដែលបដិសេធថាគាត់បានថ្លែងបែបនេះទេ ប៉ុន្តែគ្រាន់តែអះអាងថាគាត់មិនអាចចងចាំបាន ហើយប្រសិនបើគាត់បានថ្លែងបែបនេះមែន វាគ្រាន់តែជាពាក្យលេចសើចតែប៉ុណ្ណោះ[34]។

ឈ. ចៅក្រម Lemonde បានបង្ហាញអោយឃើញពីភាពលំអៀង និងអនាគតិនៅក្នុងករណីមួយដោយឡែកផ្សេងទៀត[35] ដែលធ្វើអោយចោទជាបញ្ហានូវអាកប្បកិរិយាខាងក្រមសីលធម៌ និងភាពសក្តិសមក្នុងការបំពេញមុខងារនៃតំណែងរបស់គាត់ ដែលបានផ្តល់អាណត្តិដោយការអនុវត្តដែលអាចទទួលយកបាននៃក្រមសីលធម៌របស់តុលាការ[36]។

ញ. កសចស បានបង្ហាញពីភាពខ្វះការប្រុងប្រយ័ត្នចំពោះសុវត្ថិភាពរបស់សាក្សី ។ សុវត្ថិភាពរបស់សាក្សីត្រូវបានបំផ្លាញតាមរយៈ៖

- ការអនុញ្ញាតឲ្យសមាជិកនៃក្រុមថតខ្សែភាពយន្តពិនិត្យមើលទិន្និន័យសាក្សីសម្ងាត់[37]។
- ការផ្តល់ព័ត៌មានសម្ងាត់ទាក់ទងនឹងឋានានុក្រមនៅ ស២១ ទៅឲ្យក្រុមថតខ្សែភាពយន្ត[38]។
- ការអនុញ្ញាតឲ្យក្រុមថតខ្សែភាពយន្តលួចថតយកសម្លេងក្នុងការសម្ភាសន៍សាក្សីខាងក្នុង

---

33 ដូចជើងទំព័រខាងលើ។

34 *ករណី អៀង សារី* សំណុំរឿង ០០២/០៩-១០-២០០៩- អវតក/ អបជ (១), ចម្លើយតបរួមរបស់សហចៅក្រមស៊ើបអង្កេត Marcel Lemonde ទៅនឹងបណ្តឹងជំទាស់ដែលដាក់ក្នុងនាមលោក អៀង សារី និង ខៀវ សំផន, ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ 4, 00399405-00399416, កថាខណ្ឌទី៨។

35 *សូមមើល* ឧបសម្ព័ន្ធសម្ងាត់បំផុត ។

36 មេធាវីការពារក្តី កំពុងដំណើរការស្វែងរកនូវលទ្ធភាពដើម្បីដាក់ស្នើសុំជាផ្លូវការនូវបណ្តឹងករណីក្រមសីលធម៌ប្រឆាំងនឹងចៅក្រម Lemonde។

37 សូមមើល *ករណី អៀង សារី* សំណុំរឿង ០០២/១១-១១-២០០៩- អវតក/ អបជ (០៧), បណ្តឹងជំទាស់លើកទី២ស្របតាមវិធាន៣៤ របស់លោក អៀង សារី ប្រឆាំងចៅក្រម Marcel Lemonde និងបណ្តឹងជំទាស់ រួមរបស់ អៀង ធីរិទ្ធ ប្រឆាំងចៅក្រម Marcel Lemonde និងសំណើសុំសវនាការជាសាធារណៈ, ឯកសារ , ERN: 00414160-00414179, កថាខណ្ឌទី១(គ), ឧបសម្ព័ន្ធ១។

38 ដូចជើងទំព័រខាងលើ។

00658311



ដោយសម្ងាត់ ដោយគ្មានការដឹងឮ ឬគ្មានការឯកភាពពីសាក្សី[39]។

- ការអនុញ្ញាតសមាជិក កសចស ដែលគ្មានការបណ្តុះបណ្តាលពិសេសឱ្យទៅពិនិត្យមើលទិន្នន័យសាក្សីខាងក្នុង[40] និង
- ការមិនអើពើចំពោះការអះអាងពីការគំរាមកំហែងសាក្សីសក្ខានុពលជាជាងធ្វើការតាមដានដល់ពាក្យបណ្តឹងទាំងនេះ[41]។

ង. កសចស បានប្រើអ្នកបកប្រែដែលគ្មានគុណសម្បត្តិផ្នែកច្បាប់ឱ្យសង្ខេបចម្លើយរបស់សាក្សី[42]។ បញ្ហានេះ អាចនាំឱ្យព័ត៌មានសំខាន់មិនត្រូវបានដាក់បញ្ចូលដោយអចេតនាទៅក្នុងការសង្ខេបនោះ។

ច. កសចស បានបដិសេធមិនព្រមចេញដីកាកោះម្តងទៀត និងមិនបានជម្រុញឱ្យមានកិច្ចខិតខំប្រឹងប្រែងចំបាច់ ដើម្បីដាក់ឱ្យសាក្សីសក្ខានុពលជាច្រើនអនុវត្តតាមដីកាកោះទាំងនេះ ទោះបីជា ចៅក្រម Lemonde បានទទួលស្គាល់ថាសាក្សីទាំងនេះ ទំនងជាអាចផ្តល់ឱ្យតុលាការនូវភស្តុតាងពាក់ព័ន្ធ[43]។

ឆ. កសចស បានបើកការស៊ើបអង្កេតរបស់ខ្លួនជាមួយនឹងជំនឿដោយខុសឆ្គងថា ខ្លួនអាចពឹងផ្អែកលើ "គោលការណ៍នៃភាពគ្រប់គ្រាន់"។ កសចស បានលើកឡើងថា៖ "ភាពសម

[39] ដូចជើងទំព័រខាងលើ។

[40] ដូចជើងទំព័រខាងលើ, ១(ឃ), ឧបសម្ព័ន្ធ១។

[41] សូមមើល *ករណី អៀង សារី,* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក-កសចស, សំណើសុំព័ត៌មានទាក់ទងនឹង ពាក្យបណ្តឹងដែលធ្វើឡើងដោយសាក្សីសក្ខានុពល, ចុះថ្ងៃទី១ ខែមិនា ឆ្នាំ២០២០, ឯកសារ A363, ERN: 00482726-00482727។

[42] សូមមើល *ករណី អៀង សារី,* សំណុំរឿង ០០២/១១-១២-២០០៩- អវតក/អបជ(០៧), បណ្តឹងតាមវិធាន៣៤ លើកទីពីររបស់លោក អៀង សារី សុំជិតចិត្តចៅក្រម Marcel Lemonde និងការចូលរួមក្នុងបណ្តឹងរបស់មេធាវីការពារ អៀង ធីរិទ្ធ សុំជិតចិត្តសហចៅក្រមស៊ើបអង្កេត Marcel Lemonde និងសំណើសុំសវនាការសាធារណៈ: ឯកសារលេខ 1, ERN: 00414160-00414179 កថាខណ្ឌ ១(ក) ឧបសម្ព័ន្ធ ១។

[43] សូមមើល *ករណី អៀង សារី,* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក-កសចស, ដីកាសម្រេចលើសំណើរបស់ អៀង សារី និង នួន ជា សុំកោះហៅសាក្សី, ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០, ឯកសារ D314, ERN: 00446652-00446658។ *ករណី អៀង សារី,* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក-កសចស, កំណត់សម្គាល់របស់ចៅក្រម Marcel Lemonde ទាក់ទងទៅនឹងដីកាសម្រេចរបស់លើសំណើរបស់ អៀង សារី និង នួន ជា សុំកោះហៅសាក្សី,ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០, ឯកសារ D301, ERN: 00455446-00455449។

ហេតុផលក្នុងការគាំទ្រការស៊ើបអង្កេតនេះ គឺថាគោលករណ៍នៃភាពគ្រប់គ្រាន់នៃភស្តុតាងសំខាន់ជាងគោលការណ៍នៃការប្រើឱ្យអស់ពីលទ្ធភាព។ មានន័យថាសហចៅក្រមស៊ើបអង្កេត អាចបិទការស៊ើបអង្កេតរបស់ខ្លួននៅពេលដែលខ្លួនកំណត់ថាមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ជនត្រូវចោទ[44]" ។ ជំនឿខុសទៅលើគោលជំហរនេះ ត្រូវបានពន្យល់ដោយអង្គបុរេជំនុំជម្រះថា៖

អនុលោមតាមវិធាន ៥៥ (៥) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចស៊ើបអង្កេតភស្តុតាងដោះបន្ទុក ។ ដើម្បីបំពេញកាតព្វកិច្ចនេះ សហចៅក្រមស៊ើបអង្កេត ត្រូវតែពិនិត្យឯកសារ ឬសម្ភារៈដទៃទៀតនៅពេលដែលមានមូលហេតុបឋមអាចឱ្យគេជឿជាក់ថា ឯកសារ ឬសម្ភារៈទាំងនោះ អាចមានភស្តុតាងដោះបន្ទុក។ ការពិនិត្យនេះ ត្រូវធ្វើឡើង<u>មុនពេល</u>ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបិទការស៊ើបអង្កេតរបស់ខ្លួន <u>ដោយមិនគិតថាតើសហចៅក្រមស៊ើបអង្កេតអាចមាន ឬមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បី បញ្ជូនសំណុំរឿងទៅជំនុំជម្រះឬអត់នោះទេ</u>។ ក្នុងន័យនេះ វិធានផ្ទៃក្នុង ចង់គូសបញ្ជាក់ថា ចៅក្រមស៊ើបអង្កេតត្រូវតែបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួនជាមុនសិនដែលមានន័យថា សហចៅក្រមស៊ើបអង្កេតត្រូវតែសម្រេចឱ្យបាននូវការសកម្មភាពទាំងអស់ដែលខ្លួនចាត់ ទុកថាមានការចាំបាច់ដើម្បីបញ្ជាក់ពីការពិតទាក់ទងទៅនឹងអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមុនពេលវាយតម្លៃថា តើការចោទប្រកាន់នោះគ្រប់គ្រាន់ដើម្បីបញ្ជូនជនជាប់ចោទទៅកាន់ទៅជំនុំជម្រះ ឬក៏ថាត្រូវច្រានចោលការចោទប្រកាន់... ការលើកជាសំអាងថា ចៅក្រមស៊ើបអង្កេតអាចបិទការស៊ើបអង្កេតនៅពេលដែលគាត់បានកំណត់ថាវាមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ជនត្រូវចោទ នោះសហចៅក្រមស៊ើបអង្កេតបានមើលរំលងកាតព្វកិច្ចបឋម ដែលត្រូវបញ្ចប់ការស៊ើបអង្កេតជាមុនសិនមុនពេលវាយតម្លៃថាតើករណីនេះត្រូវបញ្ជូនទៅជំនុំជម្រះ ឬអត់ ។ ជំហានដំបូងនេះ គឺចាំបាច់ណាស់ដើម្បីធានាថាសហចៅក្រមស៊ើបអង្កេត បានបំពេញតួនាទីរបស់ពួកគេដើម្បីស្វែងរក និងពិចារណាពីភស្តុតាងដោះបន្ទុកដែលត្រូវបញ្ជូនដោយស្មើភាពគ្នាទៅកាន់

[44] *ករណី អៀង សារី*, សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដោះបន្ទុកក្នុងឃ្លាំងឯកសាររួម,ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩, ឯកសារ D164/2, ERN: 00343271-00343278, កថាខណ្ឌទី៦។

អង្គជំនុំជម្រះសាលាដំបូងផងដែរ។ ដោយការបកស្រាយកាតព្វកិច្ចខុសក្នុងការស្វែងរកភស្តុតាងដោះបន្ទុក អង្គបុរេជំនុំជម្រះ យល់ឃើញថាសហចៅក្រមស៊ើបអង្កេតមានកំហុសផ្នែកអង្គច្បាប់[45]។

កសចស នៅតែបន្តអនុវត្តតាមគោលការណ៍នៃភាពគ្រប់គ្រាន់ទោះជាមានការពន្យល់បែបនេះពីអង្គបុរេជំនុំជម្រះ ក៏ដោយ។ ឧទាហរណ៍ ចៅក្រម Lemonde បានទទួលស្គាល់ថាការស៊ើបអង្កេត បានបញ្ចប់ទោះបីជាគេមិនទាន់ទទួលភស្តុតាងពាក់ព័ន្ធក៏ដោយ។ លោក Lemonde បានថ្លែងនៅក្នុងសន្និសីទកាសែតមួយថា៖

> យើងមិនអាចទទួលបានអ្វីដែលយើងចង់បាននោះទេ។ យើងមិនអាចស្តាប់ចម្លើយសាក្សី មួយចំនួនបានឡើយ។ គ្មានព័ត៌មានអ្វីឡើយ។ ជួនកាល យើងជួបបញ្ហាក្នុងការទទួលបាន ចម្លើយពីរដ្ឋាភិបាលដែលយើងបានសួរ[46]។

មេធាវីការពារក្តី បានស្នើឱ្យចៅក្រម Lemonde ផ្តល់ការបញ្ជាក់ និងលាត្រដាងបន្ថែមទៀតទាក់ទងនឹងពាក្យសំដីទាំងនេះ[47] ប៉ុន្តែ កសចស បានច្រានចោលសំណើររបស់មេធាវីការពារក្តី ដោយអះអាងថាខ្លួនលែងទទួលបានសំណុំរឿងទៀតហើយ[48]។

ឈ. កសចស មិនអនុញ្ញាតឲ្យមេធាវីការពារក្តីមានវត្តមានក្នុងអំឡុងនៃការធ្វើកោសលវិច្ច័យផ្នែកចិត្តសាស្ត្រ របស់លោក អៀង សារី ដូចតាមការស្នើសុំរបស់លោក អៀង សារី ឡើយ[49]

---

[45] *ករណី អៀង សារី,* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស(អបជ២៥), សាលដីកាលើបណ្តឹងឧទ្ធរណ៍ពីដីកាសម្រេចលើសំណើស្វែងរកភស្តុតាងដោះបន្ទុកក្នុងឃ្លាំងឯកសាររួម,ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ២០០៩, ឯកសារ D164/3/6 ERN: 00384466-00384483, កថាខណ្ឌទី៣៥ ដល់៣៧ (គូសបញ្ជាក់បន្ថែម)។

[46] Julia Wallace, មេដឹកនាំខ្មែរក្រហម៤នាក់ដែលត្រូវបានចោទប្រកាន់ នឹងត្រូវបានគេកាត់ទោស, កាសែត ឌឹ ឃែមបូឌាដេលី, ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០។

[47] ករណី អៀង សារី, សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, សំណើរបស់លោក អៀង សារី សុំការបញ្ជាក់ និងបង្ហាញ ទាក់ទងទៅនឹងពាក្យសំដីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde នៅក្នុងសន្និសីទកាសែតរបស់ កសចស កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ដោយប្រកាសពីការចេញដីកាដំណោះស្រាយ, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ 1.3, ERN: 00612411-00612421។

[48] ករណី អៀង សារី, សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ការជូនដំណឹងអំពីការដាក់ឯកសារមិនគ្រប់គ្រាន់, ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១០។

[49] *ករណី អៀង សារី,* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, កម្មវត្ថុ៖ សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំដាក់ឯកសារក្នុងសំណុំរឿង, ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩, ឯកសារ D219/3, ERN: 00390852, កថាខណ្ឌទី២៖

ថ្វីបើ ករណីនេះអាចអនុញ្ញាតអោយមេធាវីការពារក្តីអាចសម្រេចថា តើវាចាំបាច់ដើម្បីស្នើសុំអ្នកជំនាញបន្ថែមទៀតឬអត់។

ណ. កសចស មិនបានដោះស្រាយការជំទាស់ខាងយុត្តាធិការដូចជាការអនុវត្តទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិសញ្ញាទីក្រុងហ្សឺណែវ និងការទទួលខុសត្រូវរបស់ថ្នាក់លើរហូតទល់តែដល់ពេលចេញដីកាដំណោះស្រាយ[50] ទោះបី សេចក្តីសម្រេចលើបញ្ហាទាំងនេះ អាចបញ្ចប់ដំណើរការនីតិវិធីជំនុំជម្រះក្តី ក៏ដោយ ។ ករណីនេះបញ្ជាក់ថា កសចស មិនដែលមានបំណងពិចារណាឲ្យបានម៉ត់ចត់អំពីការជំទាស់ទាំងនេះឡើយ ឬក៏ កសចស បានសម្រេចពីបញ្ហាទាំងនេះភ្លាមៗ។

ត. កសចស ខកខានមិនបានសម្រេចលើការអនុវត្តសហឧក្រិដ្ឋកម្មរួមរហូតស្ទើរតែចុងបញ្ចប់

---

"មេធាវីការពារក្តីលោក អៀង សារី មានបំណងចង់ឲ្យសហមេធាវីការពារក្តីរបស់គាត់ម្នាក់មានវត្តមានក្នុងអំឡុងពេលនៃការធ្វើកោសលវិច្ច័យផ្នែកចិត្តសាស្ត្រ ដើម្បីធានាថាសិទ្ធិនេះ ត្រូវបានគេគោរព"។ ករណី អៀង សារី, សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, កោសលវិច្ច័យផ្នែកចិត្តសាស្ត្រ, ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩, ឯកសារ A305, ERN: 00386397-00386398។

[50] ផ្ទុយទៅវិញ កសចស បានគូសបញ្ជាក់ច្រំដែលៗថា ខ្លួនអាចមិនពិចារណាពីការជំទាស់ខាងយុត្តាធិការ នៅក្នុងតំណាក់កាលស៊ើបសអង្កេត ព្រោះវា "គ្មានការតម្រូវ និង មិនត្រូវបានវិនិច្ឆ័យទុកជាមុននូវការកំណត់ប្រភេទនៃបទល្មើសរហូតដល់មានដីកាដំណោះស្រាយ"។ *ករណី អៀង សារី*, សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ដីកាសម្រេចលើញ្ញាតិរបស់ អៀង សារី ប្រឆាំងទៅនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ, ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ ២០១០, ឯកសារ D345/4, ERN: 00487605-00487608, កថាខណ្ឌទី១១។ សូមមើលផងដែរ *ករណី អៀង សារី*, សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ដីកាសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រកំណត់, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០, ឯកសារ, D345/1, ERN: 00452734-00452736, កថាខណ្ឌទី៥។ *ករណី អៀង សារី*, សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំបើកកិច្ចស៊ើបសួរ ទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ ERN:00417295-00417299, កថាខណ្ឌទី៧។ *ករណី អៀង សារី*, សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងទៅនឹងការអនុវត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅអវតក , ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ D240/3, ERN: 00421137-00421140 កថាខណ្ឌទី៥។ *ករណី អៀង សារី*, សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងទៅ នឹងការរៀបអាពាហ៍ពិពាហ៍ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ, ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ D268/2, ERN: 00417249-00417254,កថាខណ្ឌទី៩។

00658315



នៃការស៊ើបអង្កេត[51]។ ដូច្នេះហើយគេនៅតែមានមន្ទិលសង្ស័យថាតើអត្ថិភាពនៃផែនការរួមអាចត្រូវបានគេស៊ើបអង្កេតឱ្យបានត្រឹមត្រូវដែរឬយ៉ាងណា។

ថ. កសចស បដិសេធសំណើរបស់មេធាវីការពារក្តីដោយមិនបានផ្តល់សំអាងហេតុ ឬការពន្យល់ឱ្យបានសមហេតុផលណាមួយឡើយ[52] ហើយ កសចស បានចេញការព្រមានដល់មេធាវីការពារក្តី ចំពោះការធ្វើសំណើដែលមានសុពលភាព ជាជាងធ្វើការឆ្លើយតបទៅនឹងខ្លឹមសារចំពោះសំណើបែបនេះ[53]។

ទ. បន្ទាប់ពីបានបិទការស៊ើបអង្កេត កសចស បានបដិសេធមិនព្រមផ្តល់ឱ្យភាគីនូវសំណៅ CaseMap របស់ខ្លួនឡើយ ។ សំណៅនេះ អាចភ្ជាប់អង្គហេតុសត្យាម័តនីមួយទៅនឹងបំណែកនៃភស្តុតាងដោះបន្ទុក ឬដាក់បន្ទុក ក៏ដូចជាធាតុផ្សំនីមួយៗនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ និងធាតុផ្សំនីមួយៗដែលបង្កើតបានជាទម្រង់នៃការចូលរួមប្រព្រឹត្ត។ នេះអាចជាវិធីសាស្ត្រដ៏ច្បាស់លាស់បំផុត ដែលភាគីទាំងអស់អាចយកទៅវាយតម្លៃថាតើ កសចស ពិតជាបានស៊ើបអង្កេត និងវិភាគយ៉ាងយកចិត្តទុកដាក់រាល់ភស្តុតាងដោះបន្ទុកទាំងអស់ដែរឬអត់។ ករណីនេះក៏នឹងធានាផង ដែរថា កសចស បានកំណត់ពីអង្គហេតុសត្យានុម័តឱ្យបានលម្អិតគ្រប់គ្រាន់ ដើម្បីជៀសវាងបញ្ហាមួយចំនួនដែល

---

[51] សូមមើល *ករណី អៀង សារី* ,សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ដីកាសម្រេចលើការអនុវត្តនៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០០៩, ឯកសារ D97/13, ERN: 00411047-00411056។ ករណី អៀង សារី ,សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ការជូនដំណឹងអំពីការបិទការស៊ើបអង្កេត, ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០, ឯកសារ D317, ERN: 00428885-00428886។

[52] សូមមើល ឧទាហរណ៍ ចម្លើយតបទៅនឹងសំណើរបស់ អៀង សារី សុំឱ្យគេផ្តល់ឱ្យមេធាវីការពារក្តីនូវតារាងវិភាគភស្តុតាង, ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ ២០១០, ឯកសារ A372/1, ERN: 00495269-00495269។ *ករណី អៀង សារី* ,សំណុំរឿង ០០២ /១៩-០៩-២០០៧- អវតក/កសចស, ចម្លើយតបទៅនឹងសំណើរបស់ អៀង សារី សុំថតសម្លេងនិងវីដេអូ លោក អៀង សារី ក្នុងមន្ទីរឃុំឃាំងនៅ អវតក, ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ ២០១០, ឯកសារ A371/1, ERN: 00495263-00495264។ *ករណី អៀង សារី* ,សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, លិខិតរបស់ អៀង សារី ទៅកាន់ កសចស៖ លិខិតរបស់លោកឆ្លើយតបនឹងសំណើរបស់យើងខ្ញុំសុំកំណត់វិសាលភាពនៃកាតព្វកិច្ចរបស់អ្នកស៊ើបអង្កេតរបស់ កសចស គឺលោក Stephen Heder, ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០,ឯកសារ ERN: 00507782-00507783។

[53] សូមមើល ឧទាហរណ៍ *ករណី អៀង សារី* ,សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ដីកាសម្រេចព្រមានអនុលោម តាមវិធាន៣៨, ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០, ឯកសារ D367, ERN: 00478513-00478519។

កសចស បានជួបប្រទះក្នុងដីកាដំណោះស្រាយលើករណី ឌុច[54]។

ធ. កសចស បានបដិសេធមិនឲ្យមេធាវីការពារក្តីថតសម្លេងកិច្ចប្រជុំរបស់មេធាវីការពារក្តីជាមួយ នឹងលោក អៀង សារី ដែលការថតសម្លេងនេះជាប្រយោជន៍ដល់មេធាវីការពារក្តីអន្តរជាតិ[55]។ មូលហេតុតែមួយគត់របស់ កសចស សម្រាប់គាំទ្រការបដិសេធរបស់ខ្លួន គឺថាកិច្ចព្រមព្រៀងច្បាប់ស្តីពីការបង្កើត អវតក និងកតិកាសសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") មិនបានបញ្ជាក់ច្បាស់ថា ការថតសម្លេងបែបនេះត្រូវបានអនុញ្ញាតនោះទេ![56] សេចក្តីសម្រេចនេះ ត្រូវបានបដិសេធចោលនៅពេលមានការប្តឹងឧទ្ធរណ៍[57]។

ន. កសចស ហាក់បីដូចជាបានអនុវត្តផ្សេងៗពីគ្នានូវសំណើសុំដាក់ភស្តុតាងក្នុងសំណុំរឿង ដោយផ្អែកតាមបញ្ហាថាតើភស្តុតាងបែបនេះ ត្រូវបានដាក់ដោយ កសព ឬដោយក្រុមមេធាវីការពារក្តី។ ឧទាហរណ៍ សំណើរបស់ កសព ស្នើឲ្យបន្ថែមសៀវភៅចំនួន២១ ក្បាលទៅក្នុងសំណុំរឿង ត្រូវបានទទួលទាំងស្រុងក្នុងរយៈពេល១ខែដោយគ្មានសំអាងហេតុ ឬការយោងទៅនឹងបទដ្ឋានច្បាប់ជាធរមានណាមួយ នោះទេ[58]។ កសចស ក៏បានទទួលយកនូវសំណើមួយទៀតរបស់ កសព សុំដាក់សៀវភៅចំនួន១២ ក្បាលទៅ

---

[54] សូមមើល *ករណី កាំង ហ្គេកអ៊ាវ* ហៅ "ឌុច", សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ០២), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែលបញ្ជូន កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ទៅជំនុំជម្រះ, ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០០៨, ឯកសារ ERN: 00249846-00249887, កថាខណ្ឌ ៥៦ ដល់៥៧។

[55] *ករណី អៀង សារី*,សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ចម្លើយតបទៅនឹងសំណើរបស់លោក អៀង សារី សុំធ្វើការថតសម្លេង ឬថតវីដេអូ អំពីលោក អៀង សារី ក្នុងមន្ទីរឃុំឃាំង, ចុះថ្ងៃទី ៩ ខែមេសា ឆ្នាំ២០១០, ឯកសារ A371/1, ERN: 00495263-00495264។

[56] ដូចជើងទំព័រខាងលើ, ទំព័រទី១។

[57] *ករណី អៀង សារី* ,សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស (អបជ៦៤), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំអនុញ្ញាតឲ្យមានការថតសម្លេង ឬថតវីដេអូ អំពីកិច្ចប្រជុំជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង, ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១០, ឯកសារ A371/2/12, ERN: 00531173-00531191។

[58] *ករណី នួន ជា* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, សំណើរបស់លោកសុំដាក់បញ្ចូល សៀវភៅអំពីកម្ពុជាប្រជាធិបតេយ្យដែលសរសេរដោយសាក្សី និងអ្នកជំនាញ, ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩, ឯកសារ D222/1, ERN: 00392330-00392330។

ក្នុងសំណុំរឿង[59]។ កសចស បានច្រានចោល[60]សំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា សុំដាក់បញ្ចូលសៀវភៅមួយក្បាលទៅក្នុងសំណុំរឿង[61]។

ប. នៅក្នុងដីកាដំណោះស្រាយ កសចស បានទទួលស្គាល់ថា មានភាពខ្វែងគំនិតគ្នារវាងសហចៅក្រមស៊ើបអង្កេតទាក់ទងបញ្ហាថាតើមាត្រា៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក អាចយកមកអនុវត្តបានដែរឬទេ ប៉ុន្តែក្រោយមក សហចៅក្រមស៊ើបអង្កេត សម្រេចអនុវត្តមាត្រា៣ថ្មី[62] ដោយរំលោភលើគោលការណ៍នៃធម្មនុញ្ញ[63] វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (*in dubio pro reo*)។ សហចៅក្រមស៊ើប អង្កេតបានលើកឡើងស្រដៀងគ្នានេះថាពួកគេមិនអាចកំណត់ថាតើគោលការណ៍មិនជម្រះក្តីពីរដង *ne bis in dem* បានហាមឃាត់ការចោទប្រកាន់នូវពេលបច្ចុប្បន្នប្រឆាំងលោក អៀង សារី ដែរឬអត់ទេ ព្រោះមានករណីជាច្រើនទៀតនៅតែមិនទាន់ច្បាស់ទាក់ទងនឹងការជំនុំជម្រះក្តីលោក អៀង សារី កាលពីឆ្នាំ១៩៧៩[64]។ ដូច្នេះសហចៅក្រមស៊ើបអង្កេត សម្រេចទុកបញ្ហានេះឱ្យអង្គជំនុំជម្រះសាលាដំបូងដោះស្រាយ[65]។

**ខ. ការស៊ើបអង្កេតដែលលម្អៀង និងមានកំហុស ប៉ះពាល់ដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌**

៧. លោក អៀង សារី មានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដោយតុលាការដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង។ ប្រសិនបើការស៊ើបអង្កេតមានភាពលម្អៀង ឬមានកំហុស

---

[59] *ករណី នួន ជា* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សម្ភារៈភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង, ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ ២០១០, ឯកសារ D313/1, ERN: 00428802-00428805។

[60] *ករណី នួន ជា* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ដីកាសម្រេចលើសំណើទី១៨ របស់ នួន ជា សុំបើកកិច្ចស៊ើបសួរ, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០១០, ឯកសារ , D273/2, ERN: 00456261-00456264។

[61] *ករណី នួន ជា* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, សំណើទី១៨ សុំបើកកិច្ចស៊ើបសួរ, ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ D273, ERN: 00414350-00414354។

[62] *ករណី អៀង សារី* ,សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស, ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១០, ឯកសារ D427, ERN: 00604508-00605246, កថាខណ្ឌទី១៥៧៥។

[63] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ដែលបានធ្វើវិសោធនកម្មនាថ្ងៃទី ៤ មីនា ១៩៩៩, មាត្រា៣៨។

[64] ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៣២។

[65] ដូចជើងទំព័រខាងលើ, កថាខណ្ឌ១៣៣៣។

ហើយមិនមានកិច្ចខិតខំប្រឹងប្រែងដើម្បីជួសជុលកំហុសទាំងនេះ មុនពេលឆ្ពោះទៅរកការជំនុំជម្រះក្តីទេនោះ សិទ្ធិទទួលបានការជំនុំជម្រះក្តីរបស់លោក អៀង សារី នឹងត្រូវបានគេរំលោភ។ ទោះបីជាការជំនុំជម្រះក្តីត្រូវបានគេធ្វើឡើងដោយមានឯករាជ្យ និងអនាគតិពេញលេញក៏ដោយ ក៏វានៅតែមិនអាចមានឯករាជ្យ ឬអនាគតិពេញលេញដដែល ប្រសិនបើការជំនុំជម្រះក្តីនោះ ពឹងផ្អែកលើភស្តុតាងដែលបានមកពីការស៊ើបសួរ ដែលលម្អៀង និងមានកំហុស ។

៨. កំហុសឆ្គង និងភាពលម្អៀងក្នុងការស៊ើបអង្កេត មិនអាចត្រូវបានកែតម្រូវដោយសារបញ្ហាដែលថាមេធាវីការពារក្តី ត្រូវបានគេផ្តល់សិទ្ធិឱ្យដាក់សំណើសុំកិច្ចស៊ើបសួរទៅការិយាល័យសហចៅក្រមស៊ើបអង្កេតបានទេ។ ភាពលម្អៀងអាចប៉ះពាល់ដល់មធ្យោបាយក្នុងការស៊ើបអង្កេតរួមបញ្ចូលទាំងបញ្ហាថាតើសំណើរបស់មេធាវីការពារក្តីត្រូវបានគេបន្តយកចិត្តទុកដាក់តាមវិធីណា។ មេធាវីការពារក្តីត្រូវបានគេហាមមិនឱ្យធ្វើការស៊ើបសួរដោយខ្លួនឯង ដូច្នេះហើយមេធាវីការពារក្តីមិនអាចលាតត្រដាង ឬដាក់សម្ភារៈនៅក្នុងសំណុំរឿងដែលជំទាស់ទៅនឹងសម្ភារៈដែលមានកំហុស ឬលម្អៀងបានឡើយ។

៩. ជាងនេះទៅទៀត ភាពលម្អៀងក្នុងការស៊ើបអង្កេតមិនអាចត្រូវបានគេបដិសេធចោលដោយគ្រាន់តែលើកឡើងថារបាយការណ៍អំពីភាពលម្អៀងមិនអាចជឿជាក់បានទេ។ នៅពេលដែលមេធាវីការពារក្តីប្តឹងដិតចិត្តប្រឆាំងចៅក្រម Lemonde ដោយសារភាពលម្អៀងបន្ទាប់ពីគាត់បានជម្រុញឱ្យអ្នកស៊ើបអង្កេតរបស់គាត់ ឱ្យស្វែងរកភស្តុតាងដាក់បន្ទុកឱ្យបានច្រើនជាភស្តុតាងដោះបន្ទុក អង្គបុរេជំនុំជម្រះយល់ឃើញថាការថ្លែងរបស់លោក Bastin ដើម្បីយកមកគាំទ្រនោះ “មិនមានលក្ខណៈរឹងមាំខ្លាំងឡើយ[66]”។ ករណីនេះ គឺមួយផ្នែកបណ្តាលមកពីការថ្លែងនោះ មិនត្រូវបានបញ្ជាក់ ហើយគ្មានការផ្ទៀងផ្ទាត់ណាមួយអំពីអត្តសញ្ញាណរបស់លោក Bastin ត្រូវបានធ្វើឡើងនៅពេលដែលសេចក្តីថ្លែងរបស់គាត់ត្រូវបានគេទទួលយកនោះទេ[67] ។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា សេចក្តីថ្លែងក្រោយមកទៀតរបស់លោក Bastin ទាក់ទងទៅនឹងលិខិតឆ្លងឆ្លើយរវាង*ភាគីតែម្ខាង* របស់ កសព និង កសចស ត្រូវបានអង្គបុរេជំនុំជម្រះ ទទួលស្គាល់ថាមានទំងន់ច្រើនឡើង

---

[66] *ករណី អៀង សារី* ,សំណុំរឿង ០០២-០៩-១០-២០០៩- អវតក/កសចស (អបជ០១), សាលដីកាលើបណ្តឹងរបស់លោក អៀង សារី សុំដិតចិត្តសហចៅក្រមស៊ើបអង្កេត Marcel Lemonde, ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ ERN: 00407716-00407724, កថាខណ្ឌ២៣។

[67] ដូចដើងទំព័រខាងលើ, កថាខណ្ឌ២០។

ហើយក្រោយមកទៀតការថ្លែងនេះ ត្រូវបានបញ្ជាក់ដោយភស្តុតាងថាពិតជាត្រឹមត្រូវ[68] ។ ការបើកសវនាការដើម្បីសម្រេចថាតើកំហុស និងភាពលម្អៀងពិតជាបានកើតឡើងក្នុងការស៊ើបអង្កេត ហើយការយកសក្ខីកម្មពីលោក Bastin និងអ្នកដទៃទៀត នឹងក្លាយជាមធ្យោបាយដ៏ល្អបំផុត ដើម្បីសម្រេចនូវអ្វីដែលលោកចៅក្រម Lemonde បានលើកឡើង និងអត្ថន័យនៃការលើកឡើងរបស់គាត់ ។

### គ. ការស៊ើបអង្កេតដែលមានកំហុស និងលម្អៀង មិនអាចត្រូវបានកែតម្រូវដោយការចេញដីកាដំណោះស្រាយឡើយ

១០. វិធាន៧៦ (៧) ចែងថា៖ “លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើង ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ”។ ប៉ុន្តែ ដីកាដំណោះស្រាយមិនអាចកែតម្រូវកំហុសនីតិវិធីទាំងអស់ក្នុងការស៊ើបសួរបានទេ ព្រោះមេធាវីការពារក្តីគ្មានមធ្យោបាយផ្លូវច្បាប់ក្នុងអំឡុងពេលនៃការស៊ើបសួរដើម្បីដោះស្រាយកំហុសទាំងនេះបានទេ។

១១. អង្គបុរេជំនុំជម្រះ មានតែយុត្តាធិការបន្តិចបន្តួចដើម្បីបើកសវនាការលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីក្នុងអំឡុងពេលនៃការស៊ើបអង្កេត[69]។ ដូច្នេះបញ្ហាជាច្រើនដែលទាក់ទងនឹងការស៊ើបសួរត្រូវបានសម្រេច ដោយស្ថាប័នដែលមេធាវីការពារក្តីព្យាយាមចង់លើកឡើងនូវបញ្ហានោះបានធ្វើការងារដោយមានភាពលម្អៀង ឬក៏ដោយមានកំហុសឆ្គង។ ម្យ៉ាងវិញទៀត

---

[68] *ករណី អៀង សារី* ,សំណុំរឿង ០០២/១៤-១២-២០០៩- អវតក/អបជ (០៨), ប្រតិចារឹក, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០១១, ឯកសារ 22, ERN: 00649417-00649434។

[69] សូមមើលវិធាន ៧៤ (៣) ដែលបានកំណត់យុត្តាធិការរបស់អង្គបុរេជំនុំជម្រះក្នុងការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ខណៈពេលដែលវិធាន ៧៤ (២) អនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះអនុវត្តយុត្តាធិការ លើបណ្តឹងឧទ្ធរណ៍របស់កសព ។ ប៉ុន្តែ ត្រូវកត់សម្គាល់ថា ជួនកាលអង្គបុរេជំនុំជម្រះយល់ឃើញថាវិធាន ២១ តម្រូវឱ្យអង្គបុរេជំនុំជម្រះជំនុំជម្រះបណ្តឹងឧទ្ធរណ៍មួយចំនួន ដែលខ្លួនគ្មានយុត្តាធិការធ្វើការជំនុំជម្រះ ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ សូមមើល *ករណី អៀង សារី,* សំណុំរឿង ០០២/១៩-០៩-២០០៧- អវតក/កសចស (អបជ៦៤), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធសំណើ សុំថតសម្លេង/ថតវីដេអូ នូវកិច្ចប្រជុំជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង, ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ ២០១០, ឯកសារ A371/2/12, ERN: 00531173-00531191, កថាខណ្ឌទី១៨។

00658320



ដីកាដំណោះស្រាយមិនអាចត្រូវបានគេពិចារណាថា ជួសជុលនូវរាល់វិការៈនៃនីតិវិធីទាំងអស់បានទេ ព្រោះថា មេធាវីការពារក្ដីត្រូវបានគេអនុញ្ញាតអោយប្ដឹងឧទ្ធរណ៍ប្រឆាំងតែនឹងបញ្ហាយុត្តាធិការដែលលើកឡើងក្នុងដីកាដំណោះស្រាយប៉ុណ្ណោះ[70] ។ មេធាវីការពារក្ដីមិនត្រូវបានអនុញ្ញាតអោយប្ដឹងឧទ្ធរណ៍លើបញ្ហានានា ដូចជាការប្រើប្រាស់នូវភស្តុតាងដែលពាក់ព័ន្ធនឹងការធ្វើទារុណកម្មក្នុងដីកាដំណោះស្រាយ ជាអាទិ៍។

១២. ការអនុវត្តវិធាន ៧៦ (៧) ដើម្បីហាមឃាត់មេធាវីការពារក្ដីមិនឲ្យមិនឲ្យលើកឡើងពីបញ្ហាដែលបានកើតឡើងមុនការចេញដីកាដំណោះស្រាយ នឹងរំលោភលើសិទ្ធិជាមូលដ្ឋានរបស់លោក អៀង សារី ព្រោះមកទល់ពេលនេះ គាត់គ្មានមធ្យោបាយដើម្បីដោះស្រាយឲ្យបានគ្រប់គ្រាន់នូវកំហុសឆ្គងក្នុងការស៊ើបអង្កេតឡើយ។ វិធានផ្ទៃក្នុងតែត្រូវបានគេបកស្រាយថាដើម្បីការពារប្រយោជន៍របស់ជនជាប់ចោទ[71] ហើយត្រូវតែមិនយកវិធានទាំងនេះមកប្រើ ប្រសិនបើការអនុវត្តបង្កជាការរំលោភទៅនឹងសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌។ នេះជាការពិតព្រោះមេធាវីការពារក្ដី មិនបានផ្ដល់យោបល់ដោយផ្ទាល់ក្នុងការធ្វើសេចក្ដីព្រៀង ឬការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងឡើយ ព្រោះគ្រប់សំណើសុំធ្វើវិសោធនកម្មទាំងអស់ ត្រូវបានជម្រុះចោលដោយ គណៈកម្មាធិការវិធាន និងនីតិវិធី។ វិធាន៧៦ កើតចេញពីច្បាប់កម្ពុជា[72] ប៉ុន្តែច្បាប់កម្ពុជានេះគួរតែត្រូវបានគេកែសម្រួលបើគិតពិចារណាពីភាពខុសផ្លែកគ្នារវាងរឿងក្ដីនេះ និងរឿងក្ដីកម្ពុជាសាមញ្ញដទៃទៀត។ ការស៊ើបសួរក្នុងសំណុំរឿង០០២ គឺមានទំហំធំធេង និងស្មុគស្មាញច្រើនដងជាងការស៊ើបអង្កេតក្នុងតុលាការកម្ពុជាជាច្រើនទៀត ហើយឱកាសដែលនឹងកើតមានកំហុស និងភាពលម្អៀង ក៏កើតមានច្រើនជងផងដែរដោយសាតែពេលវេលាដែលបានកន្លងផុតទៅចាប់តាំងពីបទឧក្រិដ្ឋដែលបានចោទប្រកាន់នេះបានកើតឡើង និងដោយសារតែលក្ខណៈធ្ងន់ធ្ងររបស់ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នេះ។

## IV. សេចក្ដីសន្និដ្ឋាន

[70] សូមមើល ករណី អៀង សារី សំណុំរឿង ០០២/១៩-០៩-១០០៧(អបជ៧៥) សាលដីកាលើសំណើសុំជាបន្ទាន់របស់លោក អៀង សារី សុំបន្ថែមចំនួនទំព័រកំណត់ដើម្បីប្ដឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការដែលលើកឡើងក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១ តុលា ២០១០ ឯកសារលេខ D427/1/3, ERN: 00611380-00611383 កថាខណ្ឌ ១០។

[71] សូមមើលវិធាន២១ (១)។

[72] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា២៥៦។

១៣. វាហាក់បីដូចជាស្តែងឱ្យឃើញយ៉ាងច្បាស់ថាការស៊ើបអង្កេតមានភាពលម្អៀង និងមានកំហុស។ ប្រសិនបើការស៊ើបអង្កេតនេះ មិនត្រូវបានគេត្រួតពិនិត្យឱ្យបានដិតដល់ ហើយកំហុស និងភាពលម្អៀងមិនត្រូវបានគេកែតម្រូវទេនោះ ការជំនុំជម្រះក្តីដ៏យុត្តិធម៌មួយមិនអាចប្រព្រឹត្តិទៅបានទេ។ អង្គជំនុំជម្រះសាលាដំបូង ត្រូវតែបើកសវនាការមុនការជំនុំជម្រះលើអង្គសេចក្តីដើម្បីកំណត់ពីលក្ខណៈ និងកម្រិតនៃភាពលម្អៀង និងកំហុសឆ្គងក្នុងការស៊ើបអង្កេតដើម្បីឱ្យមានការកែតម្រូវដ៏ត្រឹមត្រូវមួយ។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែកោះហៅសាក្សីដែលមានព័ត៌មាន ទាក់ទងនិងភាពលម្អៀង និងកំហុសឆ្គង រួមទាំងចៅក្រម Lemonde ចៅក្រម យូ ប៊ុនឡេង លោក Wayne Bastin លោក Stephen Heder លោក David Boyle និងលោក Craig Etcheson។

## V **សំណូមពរ**

**ដូច្នេះ** អាស្រ័យលើហេតុផលដែលបានលើកឡើងក្នុងញត្តិនេះ មេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងបើកសវនាការដេញដោលទាក់ទងនឹងដំណើរការស៊ើបសួរ និងបង្ខំចៅក្រម Marcel Lemonde និងចៅក្រម យូ ប៊ុនឡេង លោក Wayne Bastin, Stephen Heder, David Boyle និងលោក Craig Etcheson និងអ្នកដែលពាក់ព័ន្ធដទៃទៀត ឱ្យផ្តល់ភស្តុតាង ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី**២៥** ខែ **មីនា** ឆ្នាំ **២០១១**

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**